ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ




# របាយការណ៍ ប្រចាំត្រីមាសទី១ ២០២២

គោលដៅយុទ្ធសាស្រ្តចម្បងរបស់ រ.ទ.ស.ភ មានដូចខាងក្រោម៖
ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នានៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក បង្កើនប្រសិទ្ធិភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និង បរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្រ្តជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: (៨៥៥)២៣ ៧២៤០៤៦
លេខទូរសារ: (៨៥៥)២៣ ៤២៧៦៥៧

អ៊ីម៉ែល:
ir@ppwsa.com.kh



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ទ្រព្យសកម្មសរុប(ពាន់រៀល) | ២.៤២៧.៨៨១.៣២០ | ២.៣០៦.៨០៦.១៧៤ | ១.៨៦៤.៦១៨.១៤០ |
| បំណុលសរុប(ពាន់រៀល) | ១.២៣៥.០០៥.៦១០ | ១.១៤០.១៧៧.៩៦១ | ៨៨២.៥៦៥.៤៨៣ |
| មូលធនសរុប(ពាន់រៀល) | ១.១៩២.៨៧៥.៧១០ | <u>១.១៦៦.៦២៨.២១៣</u> | <u>៩៨២.០៥២.៦៥៧</u> |

| លទ្ធផលហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២២ | ត្រីមាសទី១ ឆ្នាំ២០២១ | ត្រីមាសទី១ ឆ្នាំ២០២០ |
|---|---|---|---|
| ចំណូលសរុប(ពាន់រៀល) | ៨២.០២០.០១០ | ៨៤.៣០៤.៧២៦ | ៧៥.៨១៧.៣១៦ |
| ចំណេញមុនបង់ពន្ធប្រាក់ចំណេញ(ពាន់រៀល) | ៤០.៦៨៦.២៦៩ | ៤២.៤១៦.០៣៩ | ៣៣.១៥៦.៩១៣ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៣០.២៩១.៧៤៩ | ៣០.៧៧១.៦០៩ | ២៦.៦០៣.៩៤៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៣០.២៩១.៧៤៩ | ៣០.៧៧១.៦០៩ | ២៦.៦០៣.៩៤៤ |

| អនុបាតហិរញ្ញវត្ថុ | | ត្រីមាសទី១ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|---|
| **អនុបាតសាធនភាព** | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត(ចំនួនដង) | ១,៩៩ | ១,៦៥ | ១,០៨ |
| | អនុបាតចរន្តលឿន(ចំនួនដង) | ១,៣៣ | ១,១១ | ០,៦៨ |
| | | ត្រីមាសទី១ ឆ្នាំ២០២២ | ត្រីមាសទី១ ឆ្នាំ២០២១ | ត្រីមាសទី១ ឆ្នាំ២០២០ |
| **អនុបាតចំណេញភាព** | អនុបាតចំណេញធៀបនឹងទ្រពសកម្ម(ភាគរយ) | ១,២៨ | ១,៦០ | ១,៦៥ |
| | អនុបាតចំណេញធៀបនឹងមូលធន(ភាគរយ) | ២,៥៧ | ៣,០០ | ២,៨៧ |
| | អនុបាតគម្លាតចំណេញដុល | ៣៩,០៦ | ៤១,០២ | ៤១,៥០ |
| | អនុបាតគម្លាតចំណេញភាព(ភាគរយ) | ៣៦,៩៣ | ៣៦,៥០ | ៣៥,០៩ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(រៀល) | ៣៤៨.២៩ | ៣៥៣,៨១ | ៣០៥,៨៩ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ៣៩,១៥ | ១១៥,៧១ | ៣៥,៥៩ |

# ក្រាហ្វិកអំពី
# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ (លានរៀល)




## ប្រាក់ចំណេញសម្រាប់ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល)



# សមាសភាព
# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម អ៊ុំ សុថា**
រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
**ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឡុង ណារ៉ូ**
អគ្គនាយក
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម មុី វ៉ាន់**
រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម នួន ផារ័ត្ន**
អភិបាលរងនៃគណៈអភិបាល
រាជធានីភ្នំពេញ
**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ម៉ា ណូរ៉ាវីន**
តំណាងនិយោជិត
នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
**សមាជិកក្រុមប្រឹក្សាភិបាល**



**លោកឧកញ៉ា ចាន់ យុនហ្វេន**
អភិបាលមិនប្រតិបត្តិតំណាង
ភាគហ៊ុនិកឯកជន
**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក អោម សេន បូរ៉ា**
អភិបាលឯករាជ្យ
**សមាជិកក្រុមប្រឹក្សាភិបាល**

# សេចក្តីថ្លែងរបស់ ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម អ៊ុំ សុថា**
រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម
វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
**ប្រធានក្រុមប្រឹក្សាភិបាល**

## ក្នុងត្រីមាសទី១ឆ្នាំ២០២២ នេះ

"ដោយទទួលបានទំនុកចិត្តពីរាជរដ្ឋាភិបាលជាមួយ នឹងការឧបត្ថម្ភគាំទ្រពីក្រសួងអាណាព្យាបាលទាំងពីរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបំពេញកាតព្វកិច្ចដោយជោគជ័យ គ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។ យើងកំពុងបន្តអភិវឌ្ឍសេវាទឹកស្អាតជារៀងរាល់ថ្ងៃ ទាំងគុណភាព និងបរិមាណ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជននៃទីក្រុងភ្នំពេញ និងទីក្រុងតាខ្មៅនិងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍរបស់ទីក្រុងទាំងពីរ។"

ក្នុងត្រីមាសទី១ នេះ រ.ទ.ស.ភ បានទទួលចំណូលសរុប ៨២.០២០.០១០ពាន់រៀល និងប្រាក់ចំណេញមុនបង់ពន្ធ លើប្រាក់ចំណេញ ៤០.៦៨៦.២៦៩ពាន់រៀល និងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន( Basic earning per share ) គឺ ៣៤៨,២៩រៀល។

រ.ទ.ស.ភ វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែក ចាយទឹកស្អាត និងអនាម័យ។ ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម-សេវាកម្ម និងធានាគុណភាពទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម សេវាកម្ម និងឧស្សាហកម្ម។ ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់។

សហប្រតិបត្តិការលើផ្នែកបច្ចេកទេសពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍទាំងក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្មអាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្ត កសាងសមត្ថភាពរបស់សហគ្រាស វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទ ដើម្បីកាត់បន្ថយថ្លៃដើម ទឹកប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

## សេវាដ៏មានប្រសិទ្ធភាព

យើងនៅតែបន្តធានាការផ្គត់ផ្គង់ទឹកស្អាត ២៤ម៉ោងលើ២៤ម៉ោង ជាមួយនឹងគុណភាពដែលអាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។ ក្នុងត្រីមាសទី១ ឆ្នាំ២០២២ នេះ យើងបានដាក់បំពង់មេនាំទឹក និងបណ្តាញចែកចាយទឹកស្អាត សរុបប្រវែង ១១៤.៧៤៣,២១ម៉ែត្រ និងផលិតបាន ៥៦.៣៨៦.២៥១ម$^{៣}$, កំណើនអតិថិជនក្នុងគ្រា បានចំនួន ៦.៦០៦បណ្តាញ ក្នុងនោះអតិថិជនចំណូលទាបចំនួន ២០២បណ្តាញ, អត្រាទឹកបាត់បង់ស្ថិតក្នុងកម្រិត ៨,៦៤% ។

## ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

### ១- លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី១ ឆ្នាំ២០២២ (ប្រជុំលើកទី១១) អាណត្តិទី៧ របស់ រ.ទ.ស.ភ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ នេះ ក្រុមប្រឹក្សាភិបាលអាណត្តិទី៧ របស់ រ.ទ.ស.ភ បានបើកសម័យប្រជុំវិសាមញ្ញ លើកទី១ (ប្រជុំលើកទី១១) អាណត្តិទី៧ នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១០:00នាទី តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈ ដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តលើសំណើសុំតែងតាំងស្នងការគណនី

២) សំណើសុំពិនិត្យ-អនុម័តតែងតាំងបុគ្គលិកជាន់ខ្ពស់និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ

៣) របាយការណ៍បច្ចុប្បន្នភាពស្តីពីលទ្ធផលចុះអង្កេតទីតាំងអតិថិជនលក់ទឹកបន្តឱ្យកម្មករ កម្មការិនី និងសិស្សនិស្សិត នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ

៤) ផ្សេងៗ

ក) សំណើសុំពិនិត្យ-អនុម័តលើការធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះពីបញ្ជីសារពើភណ្ឌរបស់ រ.ទ.ស.ភ

ខ) សំណើសុំអនុញ្ញាតជាគោលការណ៍តែងតាំងលោក រស់ គឹមលាង ជាជំនួយការអគ្គនាយក នៅក្រោយ ពេលត្រូវបានដាក់ឱ្យចូលនិវត្តន៍

### ២- លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១២ អាណត្តិទី៧ របស់ រ.ទ.ស.ភ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ នេះ ក្រុមប្រឹក្សាភិបាលអាណត្តិទី៧ របស់ រ.ទ.ស.ភ បានបើកសម័យប្រជុំលើកទី១២ អាណត្តិទី៧ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង០៩:០០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈ ដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តបេក្ខភាពអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីធ្វើការបោះឆ្នោតជ្រើសតាំងក្នុងមហាសន្និបាតភាគហ៊ុនិក

២) សំណើសុំពិនិត្យ-អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២១ និងគោលការណ៍បែងចែកប្រាក់ចំណេញ និងបែងចែកភាគលាភដល់ភាគហ៊ុនិកឆ្នាំ២០២១

៣) របាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី១ និងផែនការត្រីមាសទី២ ឆ្នាំ២០២២

៤) សំណើសុំពិនិត្យ និងផ្តល់អនុសាសន៍ក្នុងការប្រើប្រាស់ថវិកាបដិភាគរបស់ រ.ទ.ស.ភ សម្រាប់ការងារផ្គត់ផ្គង់ និងដាក់បំពង់មេនាំទឹកឆៅទំហំ៨០០ម.ម ចេញពីស្ថានីយបូមទឹកឆៅ មករោងចក្រប្រព្រឹត្តកម្មទឹកស្អាតភូមិព្រែក ក្នុងក្របខ័ណ្ឌគម្រោងពង្រីកសមត្ថភាពផលិតទឹក៤៥.០០០ម³/ថ្ងៃ ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ក្នុងរូបភាពជា Special Purpose Company (SPC)

៥) សំណើសុំពិនិត្យ-សម្រេចអនុញ្ញាតឱ្យ រ.ទ.ស.ភ ដាក់បំពង់ទំហំ៦០០ម.ម ប្រវែង២.៨៨២ម៉ែត្រ ក្រៅផែនការ ក្នុងស្ថានភាពបន្ទាន់ នៅលើផ្លូវជាតិលេខ២ ចាប់ពីរង្វង់មូលតាខ្មៅ ដល់ស្ពានព្រែកហូរ

៦) សំណើសុំអនុញ្ញាតរៀបចំឯកសារទស្សនាទាន (Concept Note) របស់គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធជំហានទី៣ (១៣០.០០០ម³/ថ្ងៃ) និងរោងចក្រភូមិព្រែក (១០០.០០០ម³/ថ្ងៃ) និងគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងជំហានទី៣ (១៩៥.០០០ម³/ថ្ងៃ) ជូនក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៧) សំណើសុំពិនិត្យ-អនុម័តលើពិធីមហាសន្និបាតភាគហ៊ុនិកលើកទី១០

## ៣- លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី២ ឆ្នាំ២០២២ (ប្រជុំលើកទី១៣) អាណត្តិទី៧ របស់ រ.ទ.ស.ភ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ នេះ ក្រុមប្រឹក្សាភិបាលអាណត្តិទី៧ របស់ រ.ទ.ស.ភ បានបើកសម័យប្រជុំវិសាមញ្ញ លើកទី២ (ប្រជុំលើកទី១៣) អាណត្តិទី៧ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៨:៣០នាទី តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈ ដូចខាងក្រោម ៖

១) របាយការណ៍លទ្ធផលស្តីពីការសិក្សាផែនការមេ (Master Plan) ដំណាក់កាលទី៣

២) សំណើសុំពិនិត្យ-សម្រេចកញ្ចប់ហិរញ្ញវត្ថុថវិកាបដិភាគរបស់ រ.ទ.ស.ភ គម្រោងផ្គត់ផ្គង់ទឹកស្អាតទឹកស្អាត បឹងធំ ក្រោមហិរញ្ញប្បទានឥតសំណងរដ្ឋាភិបាលជប៉ុន

៣) របាយការណ៍ស្តីពីសំណើសុំកិច្ចអន្តរាគមន៍រកទុនវិនិយោគ ដើម្បីអនុវត្តគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតអាកាសយានដ្ឋានអន្តរជាតិតេជោ ក្រុងតាខ្មៅ និងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតខ្សាច់កណ្តាល

៤) សំណើសុំពិនិត្យ-អនុម័តកែសម្រួលសមាសភាពគណៈកម្មាធិការលទ្ធកម្ម

៥) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងដំណាច់ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២

៦) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គមចុងឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២

៧) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី១ ឆ្នាំ២០២២

៨) ផ្សេងៗ

ក) សំណើសុំផ្តល់អនុសាសន៍លើការត្រៀមរៀបចំសម្ពោធបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតទឹកស្អាតក្រុងតាខ្មៅ

ខ) វេទិកាផ្តល់ចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់បុគ្គលិកជាន់ខ្ពស់៨រូប ដែលទើបតែងតាំងថ្មី

រ.ទ.ស.ភ មានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការពង្រីកបណ្តាញចែកចាយទឹក ដោយមានទំនាក់ទំនងជាមួយនឹងការពង្រីកសមត្ថភាពប្រព្រឹត្តកម្ម ហើយការពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ គឺធ្វើយ៉ាងណារក្សាអត្រា និងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ និងតាំងចិត្តខ្ពស់ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

សម្រាប់ត្រីមាសទី២ឆ្នាំ២០២២ យើងគ្រោងផលិតទឹកស្អាត ៥០.៦៥២.៨៤៩ម$^3$ជាមួយនឹងការពង្រីកបណ្តាញចែកចាយទឹកបន្ថែម ៧០.៨៤៦,៩០ម៉ែត្រ និងគ្រោងចំណូលសរុប ចំនួន ៧៦.៥៦២.៩៣៣ពាន់រៀល និងចំណាយសរុបចំនួន៥៤.១៤០.៧៣០ពាន់រៀល ដូចដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលនិងក្រសួងអាណាព្យាបាលទាំងពីរ។


## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងសេចក្តីដឹងគុណដ៏ជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាល អាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលបានផ្តល់ទំនុកចិត្តនិងការគាំទ្រចំពោះ រ.ទ.ស.ភ ។

យើងក៏មានមោទនភាព និងសូមថ្លែងអំណរគុណចំពោះមន្ត្រី និងនិយោជិតគ្រប់ថ្នាក់របស់ រ.ទ.ស.ភ ដែលបានខិតខំបំពេញការងារដោយស្មារតីទទួលខុសត្រូវខ្ពស់ ជំរុញឱ្យបានសម្រេចនូវលទ្ធផលដ៏ល្អប្រសើរនេះ។


ថ្ងៃ(ទាហស្ប/ត ១០កើត) ខែ (ពិសាខ) ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី (១០) ខែ (មិថុនា) ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាភិបាល**

**អ៊ុំ សុថា**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ii

សមាសភាពក្រុមប្រឹក្សាភិបាល iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល v

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** ០១

ក- អត្តសញ្ញាណរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១

ខ- លក្ខណៈនៃធុរកិច្ច ០១

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ០២

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ០២

ខ- រចនាសម្ព័ន្ធចំណូល ០៤

**ផ្នែកទី៣: របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ០៥

**ផ្នែកទី៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ៣៤

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ៣៤

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើប្រាក់ចំណេញ ៣៨

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ៣៨

ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ៣៩

ង- ផលប៉ះពាល់នៃអតិផរណា ៣៩

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល ៣៩

**ផ្នែកទី៥: ព័ត៌មានចាំបាច់ផ្សេងៗទៀតសម្រាប់ការពារវិនិយោគិន** ៤០

# ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ក- អត្តសញ្ញាណរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- លេខកូដស្តង់ដារ: KH1000010004
- ទីស្នាក់ការ: អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរស័ព្ទ: +៨៥៥(០)២៣៦៣៥៨០៨០
- គេហទំព័រ: www.ppwsa.com.kh អ៊ីម៉ែល: ir@ppwsa.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Co.០៨៣៩Et/២០១២ កាលបរិច្ឆេទ: ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- លេខអាជ្ញាបណ្ណអាជីវកម្ម: អនុក្រឹត្យលេខ៥២អនក្រ.បក កាលបរិច្ឆេទ: ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ: ០១២/១២គ.ម.ក/ស.ស.រ. កាលបរិច្ឆេទ: ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- ឈ្មោះបុគ្គលតំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ: **ឯកឧត្តម ឡុង ណារ៉ូ**

## ខ- លក្ខណៈនៃធុរកិច្ច

- វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើន ផលិតកម្ម សេវាកម្ម និង ធានាគុណភាព ទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការ សម្រាប់ជីវភាពរស់នៅ អាជីវកម្ម សេវាកម្ម និងឧស្សាហកម្ម ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀត ដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនិងដោយអនុលោមតាមច្បាប់
- សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូអភិវឌ្ឍក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និង ហិរញ្ញវត្ថុដោយផ្សាភ្ជាប់ជាមួយផលប្រយោជន៍សង្គម
- ពង្រីកការផ្គត់ផ្គង់ទឹកនៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដាដូចគ្នានៅក្នុងរាជធានីភ្នំពេញ
- បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស
- វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក
- ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានាដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក
- តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់

### ក.១.១- លទ្ធផលការងារប្រព្រឹត្តកម្ម

➢ ការងារប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងត្រីមាសទី១ឆ្នាំ២០២២នេះ មានដូចក្នុងតារាងខាងក្រោម៖

| បរិយាយ | ផែនការ (គិតជាម៉ែត្រគូប) | អនុវត្តជាក់ស្តែង (គិតជាម៉ែត្រគូប) | អត្រា (គិតជា %) |
|---|---|---|---|
| រោងចក្រភូមិព្រែក | ១៣.៩២២.០០០ | ១៤.៣៨២.២៣៥ | ១០៣ |
| រោងចក្រជ្រោយចង្វារ | ១៥.២៩១.០០០ | ១៥.៧២៤.០១០ | ១០៣ |
| រោងចក្រចំការមន | ៤.៨៣០.៥០០ | ៥.១៩៩.០៣៤ | ១០៨ |
| រោងចក្រនិរោធ | ២១.៣៣៣.០០០ | ២០.៨៩៥.១៣០ | ៩៨ |
| រោងចក្រម្លេច | ៩៧.៣៨០ | ៩៥.៣៥៥ | ៩៨ |
| រោងចក្រត្បូងឃ្មុំ | ៧២.០០០ | ៩០.៤៨៧ | ១២៦ |
| **សរុប** | ៥៥.៤៩៥.៨៨០ | ៥៦.៣៨៦.២៥១ | ១០២ |

➢ គុណភាពទឹកតាមបណ្តារោងចក្រប្រព្រឹត្តកម្មទឹកស្អាត និងបណ្តាញចែកចាយ៖

| មុខវិភាគ | ឯកតា | WHO | រោងចក្រ ភូមិព្រែក | រោងចក្រ ជ្រោយចង្វារ | រោងចក្រ ចំការមន | រោងចក្រ និរោធ | រោងចក្រ ម្លេច | រោងចក្រ ត្បូងឃ្មុំ | បណ្តាញចែកចាយ |
|---|---|---|---|---|---|---|---|---|---|
| ភាពល្អក់ | NTU | ≤ ៥ | ០,៥៦ | ០,២៨ | ០,១៦ | ០,៣៤ | ០,៥២ | ០,៨៧ | ០,៦៥ |
| តម្លៃប៉េហាស់ | pH | ៦,៥ - ៨,៥ | ៧,១៩ | ៧,៨៤ | ៧,៦៣ | ៧,៣២ | ៧,៣៨ | ៧,៥៦ | ៧,៣៥ |
| ក្លរ័សេរី | mg/l | ០,១ - ១ | ១,៤៨ | ១,១៩ | ១,១៨ | ១,៣៤ | ១,០៣ | ០,៥៦ | ០,៣២ |
| ក្លរ័សរុប | mg/l | <២ | ១,៧០ | ១,៣៣ | ១,៣៧ | ១,៥៦ | ១,២៧ | ០,៧២ | ០,៤៥ |
| មេរោគកូលីហ្វម | cfu/100ml | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| មេរោគអ៊ីកូលី | cfu/100ml | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |

### ក.១.២- លទ្ធផលការងាររៀបចំប្រព័ន្ធចែកចាយទឹកស្អាត

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ (គិតជាគីឡូម៉ែត្រ)



## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹកនិងការងារកាត់បន្ថយទឹកបាត់បង់ (ត)

### ក.១.៣- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់

អត្រាទឹកបាត់បង់របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ មានអត្រា ៨,៦៤% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។

ក្រាហ្វិចបង្ហាញពីអត្រាទឹកបាត់បង់ពីឆ្នាំ២០០៥ ដល់ត្រីមាសទី១ ឆ្នាំ២០២២ (គិតជាភាគរយ)




## ក.២- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម

### ក.២.១- ការងារផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋមានចំណូលទាប

បណ្ដាញអតិថិជនមានចំណូលទាប ក្នុងគ្រាតាមបណ្ដាឆ្នាំនីមួយៗ




### ក.២.២- ការងារតបណ្ដាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន

| ប្រភេទអតិថិជន | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ត្រីមាសទី១ ២០២២ | |
|---|---|---|---|---|---|---|
| | (ចំនួនបណ្ដាញ) | (ចំនួនបណ្ដាញ) | (ចំនួនបណ្ដាញ) | (ចំនួនបណ្ដាញ) | (ចំនួនបណ្ដាញ) | (ភាគរយ) |
| ជីវភាព | ៣០១.៨៣៤ | ៣២១.២១២ | ៣៣៣.០៩៩ | ៣៥០.៤៦៣ | ៣៩៣.០២០ | ៨០,៦៣៨១ |
| អាជីវកម្ម | ៥៨.៧៨៩ | ៦២.៣៦៦ | ៦៨.១៣៦ | ៧៤.៣៤៤ | ៧៨.១១០ | ១៧,៨៤២២ |
| អង្គភាពរដ្ឋ | ៦៦៤ | ៦៩៦ | ៧៤៤ | ៨២៣ | ៨៧៨ | ០,២០០៦ |
| អ្នកលក់ទឹក | ០៧ | ០៧ | ១០ | ១១ | ១១ | ០,០០២៥ |
| តំណាងចែកចាយ | ២១ | ១៧ | ១៤ | ១៦ | ១៥ | ០,០០៣៤ |
| Standpipe | ១៤ | ១៧ | ១៧ | ១៦ | ១៦ | ០,០០៣៦ |
| បន្ទប់ជួល | ៥.៧០៣ | ៥.៧៥២ | ៥.៧៥៩ | ៥.៧២៨ | ៥.៧៣៣ | ១,៣០៩៥ |
| **សរុប** | **៣៦៧.០៣២** | **៣៩០.០៦៧** | **៤០៧.៧៧៩** | **៤៣១.៤០១** | **៤៣៧.៧៨៣** | |

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក.៣- ការងារគ្រប់គ្រងធនធានមនុស្ស




## ខ- រចនាសម្ព័ន្ធចំណូល

| ល. រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២២ (ពាន់រៀល) | ភាគរយ | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | ភាគរយ | ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល) | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ចំណូលពីការលក់ | ៦៩.១៣២.១២៧ | ៨៤,២៩ | ៦៨.៧២៩.០៦៣ | ៨១,៥២ | ៦៦.៨៨៧.៨៣៨ | ៨៨,២២ |
| ២ | កម្រៃពីសេវាសាងសង់ | ៣.៨១៦.៥៥៧ | ៤,៦៥ | ៦.៩៦៨.៣៤២ | ៨,២៧ | ១.៦៧៨.៤២២ | ២,២១ |
| ៣ | ចំណូលពីការប្តូររូបិយបណ្ណ-សុទ្ធ | - | - | ៥៤៣.៦២៦ | ០,៦៤ | - | - |
| ៤ | ចំណូលផ្សេងៗ | ៩.០៧១.៣២៦ | ១១,០៦ | ៨.០៦៣.៦៩៥ | ៩,៥៦ | ៧.២៥១.០៥៦ | ៩,៥៦ |
| | **ចំណូលសរុប** | <u>៨២.០២០.០១០</u> | | <u>៨៤.៣០៤.៧២៦</u> | | <u>៧៥.៨១៧.៣១៦</u> | |

# ផ្នែកទី៣:

# របាយការណ៍ហិរញ្ញវត្ថុ
# ដែលបានត្រួតពិនិត្យឡើង
# វិញដោយដោយសវនករឯករាជ្យ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**(Co.០៨៣៩ Et/២០១២)**

**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**

**សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២**

*លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២**

**មាតិកា** ទំព័រ


| | |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២ - ៣ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | ៤ - ៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៦ - ៧ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ៨ - ៩ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ១០ - ២៤ |
| របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២៥ - ២៦ |

*លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល៣ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលពាក់ព័ន្ធ (ត្រូវបានគេស្គាល់ថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល") បានបង្ហាញនូវភាពសមស្របគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ ៣៤ ស្តីពី "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*"។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាល

**ឡុង ណារ៉ូ**
អគ្គនាយក

**ដេង ប៉ូលីដែន**
អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច

**អ៊ុំ សុថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ មីនា ២០២២ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | ១.៨៨៤.៥៣៦.៦១៥ | ១.៨៩៣.៨៦៤.៦១៩ |
| ទ្រព្យសកម្មអរូបី | | ១២.៤៤៣.៩១៨ | ១២.៥៣០.២៧៨ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ១.៨៩៦.៩៨០.៥៣៣ | ១.៩០៦.៣៩៤.៨៩៧ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | | ១៦៤.៣៦៨.៤៣៦ | ១៤៣.៧៣១.៥០៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ១៣១.៧០០.៧៤០ | ២៤.៨៧៥.១៦៧ |
| ទ្រព្យសកម្មកិច្ចសន្យា | ៥ | ៦៣.៣៩១.០៨២ | ៦៦.០២៤.៥៨០ |
| ឥណទានផ្ដល់ឱ្យបុគ្គលិក | | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| ការវិនិយោគរយៈពេលខ្លី | ៦ | ៦៨.៤១៧.៧៨៣ | ៦៨.១៦៣.៨៣៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | ៩៥.០៦៦.០៩៥ | ៨៩.៦៥៩.៥៣៨ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ៥៣០.៩០០.៧៨៧ | ៤០០.៤១១.២៧៧ |
| **ទ្រព្យសកម្មសរុប** | | ២.៤២៧.៨៨១.៣២០ | ២.៣០៦.៨០៦.១៧៤ |
| **មូលធន និងបំណុល** | | | |
| **មូលធនរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ** | | | |
| ដើមទុន | | ៦១៩.៣១៥.៨៨៦ | ៦១៩.៣១៥.៨៨៦ |
| ទុនបម្រុង | | ៥៤៣.២៦៨.០៧៥ | ៤១៨.០៣៨.៤១០ |
| ចំណេញរក្សាទុក | | ៣០.២៩១.៧៤៩ | ១២៩.២៧៣.៩១៧ |
| **មូលធនសរុប** | | ១.១៩២.៨៧៥.៧១០ | ១.១៦៦.៦២៨.២១៣ |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ មីនា ២០២២ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ៧ | ៧៩៥.៦៥៨.០៧៦ | ៧៩០.៣៥៩.៧៥០ |
| ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | ១៦.៣០៩.៧០៩ | ១៦.៨១២.១៨៦ |
| បំណុលពន្ធពន្យា | | ៧៥.០១៥.៦៨៤ | ៧២.៣០៧.២៥៩ |
| គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៨ | ៧០.៨៩៥.៨០៦ | ៦៩.៤៤៦.០៧៣ |
| **បំណុលរយៈពេលវែងសរុប** | | ៩៥៧.៨៧៩.២៧៥ | ៩៤៨.៩២៥.៣០៨ |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៨ | ២៣៩.៤១៥.០១២ | ១៩១.៩៦៩.៥៤៥ |
| ប្រាក់កម្ចី | ៧ | ២៣.៩៨៧.៣០០ | ២៣.១២៨.៥១៨ |
| បំណុលកិច្ចសន្យា | ៥ | ១.៧៨៨.៨៩៤ | ១.៧៨៨.៨៩៤ |
| បំណុលពន្ធលើប្រាក់ចំណូល | | ១១.៩៣៥.១២៩ | ២៤.៣៦៥.៦៩៦ |
| **បំណុលរយៈពេលខ្លីសរុប** | | ២៧៧.១២៦.៣៣៥ | ២៤១.២៥២.៦៥៣ |
| **បំណុលសរុប** | | ១.២៣៥.០០៥.៦១០ | ១.១៩០.១៧៧.៩៦១ |
| **មូលធន និងបំណុលសរុប** | | ២.៤២៧.៨៨១.៣២០ | ២.៣០៦.៨០៦.១៧៤ |

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២២ គិតជាពាន់រៀល | ៣១ មីនា ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការលក់ | ៩ | ៦៩.១៣២.១២៧ | ៦៨.៧២៩.០៦៣ |
| កម្រៃពីការសាងសង់ | | ៣.៨១៦.៥៥៧ | ៦.៩៦៨.៣៤២ |
| ចំណេញពីការប្តូររូបិយប័ណ្ណ - សុទ្ធ | | - | ៥៤៣.៦២៦ |
| ចំណូលផ្សេងៗ | | ៩.០៧១.៣២៦ | ៨.០៦៣.៦៩៥ |
| | | ៨២.០២០.០១០ | ៨៤.៣០៤.៧២៦ |
| **ចំណាយ៖** | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (១៤.៨៧៨.៨៣៨) | (១២.៦២០.៩៨៥) |
| ចំណាយថ្លៃភ្លើង | | (៨.៥២៣.៦៥៩) | (៨.៩៨៦.៧៩៤) |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ | | (១៦.០៥៤.៤៦៨) | (១៤.៦៨៥.៩៩២) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | | (២.៥៧៩.៩៩៣) | (២.៩១២.៥៨៨) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទឹកតាមគេហដ្ឋាន | | (១.១៥៤.០៨៩) | (៧៥៣.៣០៥) |
| ចំណាយជួសជុល និងថែទាំ | | (១.៣៥៩.៤៥០) | (១.៣៧៣.៧០១) |
| ចំណាយសេវាសាងសង់ | | (១.៩៩១.០២៨) | (៦.៥០៧.៣៥០) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (២.៣១៦.០៤៦) | (១.៩២១.៨៥៧) |
| ខាតពីការប្តូររូបិយប័ណ្ណ - សុទ្ធ | | (១.១២៦.៩០៤) | - |
| | | (៤៩.៩៨៤.៤៧៥) | (៤៩.៧២២.៥៧២) |
| **ចំណេញប្រតិបត្តិការ** | | **៣២.០៣៥.៥៣៥** | **៣៤.៥៨២.១៥៤** |
| ចំណូលការប្រាក់ | ១០ | ៩.៤៦៨.៩០៧ | ៨.១៣២.៧៤២ |
| ចំណាយការប្រាក់ | ១១ | (៨១៨.១៧៣) | (២៩៨.៨៥៧) |
| **ចំណេញមុនបង់ពន្ធ** | | **៤០.៦៨៦.២៦៩** | **៤២.៤១៦.០៣៩** |
| ពន្ធលើប្រាក់ចំណូល | ១២ | (១០.៣៩៤.៥២០) | (១១.៦៤៤.៤៣០) |
| **ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា** | | **៣០.២៩១.៧៤៩** | **៣០.៧៧១.៦០៩** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២២ គិតជាពាន់រៀល | ៣១ មីនា ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិក រ.ទ.ស.ភ | | | |
| ចំណេញក្នុងមួយភាគហ៊ុនគោល (គិតជាប្រាក់រៀល) | | ៣៤៨.២៩ | ៣៥៣.៨១ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (គិតជាប្រាក់រៀល) | | ៣៤៨.២៩ | ៣៥៣.៨១ |

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

*លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | ដើមទុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | មូលធនសរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **មិនបានធ្វើសវនកម្ម** | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **១២៩.២៧៣.៩១៧** | **១.១៦៦.៦២៨.២១៣** |
| ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា | | - | - | ៣០.២៩១.៧៤៩ | ៣០.២៩១.៧៤៩ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | | - | ១២៥.២២៩.៦៦៥ | (១២៥.២២៩.៦៦៥) | - |
| ភាគលាភ | ១៣ | - | - | (៤.០៤៤.២៥២) | (៤.០៤៤.២៥២) |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនសរុប** | | - | **១២៥.២២៩.៦៦៥** | **(១២៩.២៧៣.៩១៧)** | **(៤.០៤៤.២៥២)** |
| **សមតុល្យនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២** | | **៦១៩.៣១៥.៨៨៦** | **៥៤៣.២៦៨.០៧៥** | **៣០.២៩១.៧៤៩** | **១.១៩២.៨៧៥.៧១០** |

*លេខបញ្ជីពាណិជ្ជកម្ម៖ Co.0៨៣៩ Et/២០១២*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | ដើមទុន<br>គិតជាពាន់រៀល | ទុនបម្រុង<br>គិតជាពាន់រៀល | ចំណេញរក្សាទុក<br>គិតជាពាន់រៀល | មូលធនសរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|---|
| **មិនបានធ្វើសវនកម្ម** | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | | **៥៤១.២២៧.២៨២** | **៣៥២.៤៧៣.៥៣០** | **៨៨.៣៥១.៨៤៥** | **៩៨២.០៥២.៦៥៧** |
| ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា | | - | - | ៣០.៧៧១.៦០៩ | ៣០.៧៧១.៦០៩ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ការបន្ថែមដើមទុន | | ៧៨.០៨៨.៦០៤ | - | - | ៧៨.០៨៨.៦០៤ |
| ការផ្ទេរទៅគណនីទុនបម្រុង | | - | ៦៥.៥៦៤.៨៨០ | (៦៥.៥៦៤.៨៨០) | - |
| ភាគលាភ | ១៣ | - | - | (២២.៧៨៦.៩៦៥) | (២២.៧៨៦.៩៦៥) |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនសរុប** | | **៧៨.០៨៨.៦០៤** | **៦៥.៥៦៤.៨៨០** | **(៨៨.៣៥១.៨៤៥)** | **៥៥.៣០១.៦៣៩** |
| **សមតុល្យនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **៣០.៧៧១.៦០៩** | **១.០៦៨.១២៥.៩០៥** |

របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២២ គិតជាពាន់រៀល | ៣១ មីនា ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| **ចំណេញមុនបង់ពន្ធ** | | **៤០.៦៨៦.២៦៩** | **៤២.៤១៦.០៣៩** |
| នីយ័តកម្មលើ៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | | ៤៧៦.៤៣៥ | ៤០១.៨៤៣ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ១៤.៤០២.៤០៣ | ១២.២១៩.១៤២ |
| រំលស់ជំនួយពន្ធពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | (៥០២.៤៧៧) | (៥០២.៤៧៦) |
| ការជម្រះបញ្ជីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ១០៧.១៩១ | ២៥.០០៨ |
| ចំណូលការប្រាក់ | | (៨៦៤.៨៨៣) | (៤៦៣.៤៨៩) |
| ចំណាយការប្រាក់ | | ១.៨៩៦.៤៨៣ | ១.៤៦៤.៧៨២ |
| ចំណេញសុទ្ធមិនពិតពីការប្តូររូបិយប័ណ្ណ | | (៧.០៥៩.៣៤៩) | (៨.០៦១.៤៨៥) |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **៤៩.១៤២.០៧២** | **៤៧.៤៩៩.៣៦៤** |
| កើនឡើងសន្និធិ | | (៨.៦៣៧.៤២០) | (១០.៥៧៧.២០៤) |
| ថយចុះ/(កើនឡើង)គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ៧.៧២៦.១២៩ | (២.៤៩៥.៤០២) |
| កើនឡើងគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | ៩១.៤១៨.៧២៥ | ១៩.៤៧៦.៧០៧ |
| ថយចុះទ្រព្យសកម្មកិច្ចសន្យា | | ២.៦៣៣.៤៩៨ | ១.២៣៣.៦៧៨ |
| ថយចុះបំណុលកិច្ចសន្យា | | - | (១.១០៣.៩៨១) |
| កើនឡើងប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | | ១.៤៤៩.៧៣៣ | ១.០៣៦.០៥៩ |
| **សាច់ប្រាក់សុទ្ធបានពីប្រតិបត្តិការ** | | **១៤៣.៧៣២.៧៣៧** | **៥៥.០៦៩.២២១** |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២០.១១៦.៧០២) | (២៤.៧៦៦.៧៨០) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **១២៣.៦១៦.០៣៥** | **៣០.៣០២.៤៤១** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម<br>សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០២២<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០២១<br>គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (១៣០.៥៥៤.៨១៦) | (៤២.៤៩៥.៧១២) |
| ការទិញទ្រព្យសកម្មអរូបី | | (៣៩០.០៧៥) | (៥៩០.៥៨៣) |
| កើនឡើងការវិនិយោគរយៈពេលខ្លី | | (២៥៣.៩៥០) | (៦៣២.៦៣៥) |
| ការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | | (១.០៧៨.៣១០) | (១.១៦៥.៩២៥) |
| ការប្រាក់បានទទួល | | ៧៦៥.២០៩ | ៩៥៨.៩៩៤ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(១៣១.៥១១.៩៤២)** | **(៤៣.៩២៥.៨៦១)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់បានមកពីការបន្ថែមដើមទុន | | - | (១០៣.៦៥៦) |
| សាច់ប្រាក់ទទួលបានពីកម្ចី | | ២៤.៦៤២.១៤២ | ២២.៤៤៣.១៨៧ |
| ការប្រាក់បានបង់ | | (៥១៧.៥១៩) | (៧៦៥.៤៤២) |
| ការបង់សងប្រាក់កម្ចី | | (១០.៨២២.១៥៩) | (១១.៨៩៤.៥៨៨) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | **១៣.៣០២.៤៦៤** | **៩.៦៧៩.៥០១** |
| **កើនឡើង/(ថយចុះ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **៥.៤០៦.៥៥៧** | **(៣.៩៤៣.៩១៩)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមគ្រា** | | **៨៩.៦៥៩.៥៣៨** | **៥០.២១៥.៥០៥** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងគ្រា** | | **៩៥.០៦៦.០៩៥** | **៤៦.២៧១.៥៨៦** |

របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល គួរតែអានជាមួយនឹង របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

## ១. ព័ត៌មានអំពីក្រុមហ៊ុន

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ។ គោលដៅរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ មិនត្រូវបានធ្វើសវនកម្មទេ ហើយត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជា លេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

## ២. មូលដ្ឋាននៃការរៀបចំ (ត)

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនរួមបញ្ចូលគ្រប់កំណត់សម្គាល់ទាំងឡាយណាដែលជាទូទៅត្រូវបានរួមបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ ប៉ុន្តែ កំណត់សម្គាល់ពន្យល់មួយចំនួនត្រូវបានរួមបញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការ ដែលមានសារៈសំខាន់ដល់ការយល់ដឹងពីបម្រែបម្រួលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដំណើរការរបស់ រ.ទ.ស.ភ តាំងពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនាការិយបរិច្ឆេទមុន។ អាស្រ័យហេតុនេះ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសេចក្តីប្រកាសជាសាធារណៈនានា ដែលបានធ្វើឡើងដោយរបស់ រ.ទ.ស.ភ នៅអំឡុងគ្រារាយការណ៍ចន្លោះពេល។

គោលនយោបាយគណនេយ្យដែលបានអនុវត្ត គឺមានភាពដូចគ្នាទៅនឹងការិយបរិច្ឆេទហិរញ្ញវត្ថុមុន និងគ្រារាយការណ៍ចន្លោះពេលដែលពាក់ព័ន្ធ។

## ៣. កត្តារដូវកាល ឬ វដ្ត

លើកលែងតែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ប្រតិបត្តិការរបស់ រ.ទ.ស.ភ មិនត្រូវបានរងផលប៉ះពាល់ជាសារវន្តដោយកត្តារដូវកាល ឬ វដ្តនោះទេ។

## ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | **មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០២២<br>គិតជាពាន់រៀល** | **បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២១<br>គិតជាពាន់រៀល** |
|---|---:|---:|
| **ថ្លៃដើម** | | |
| សមតុល្យដើមគ្រា/ឆ្នាំ | ២.៤៣៨.៨២៣.០០៨ | ២.០៧៥.៣៦៩.៣៤៥ |
| ការទិញបន្ថែម | ១៣១.៦៣៣.១២៦ | ២៩៤.១១៥.៤១៤ |
| ការទិញដោយការបន្ថែមដើមទុន | - | ៧៨.១៩២.២៦០ |
| ការផ្ទេរ(ទៅ)/ពីសន្និធិ | (១១.៩៩៩.៥០៨) | ៧.២១២.៤៤៦ |
| ការផ្ទេរទៅទ្រព្យសកម្មអរូបី | - | (១៦.៤៣១) |
| ការផ្ទេរទៅគណនីត្រូវទទួលផ្សេងៗ * | (១១៤.៤៥២.០២៨) | - |
| ការជំរះចេញពីបញ្ជី | (១០៧.១៩១) | (១៦.០៥០.០២៦) |
| សមតុល្យចុងគ្រា/ឆ្នាំ | ២.៤៤៣.៨៩៧.៤០៧ | ២.៤៣៨.៨២៣.០០៨ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

### ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០២២<br>គិតជាពាន់រៀល | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **រំលស់បង្គរ** | | |
| សមតុល្យដើមគ្រា/ឆ្នាំ | ៥៤៤.៩៥៨.៣៨៩ | ៥០១.៧៦៧.២៤៦ |
| រំលស់ក្នុងគ្រា/ឆ្នាំ | ១៤.៤០២.៤០៣ | ៥៣.៤៩១.៩៩៣ |
| ការជំរះចេញពីបញ្ជី | - | (១០.៣០០.៨៥០) |
| សមតុល្យចុងគ្រា/ឆ្នាំ | ៥៥៩.៣៦០.៧៩២ | ៥៤៤.៩៥៨.៣៨៩ |
| **តម្លៃយោង** | | |
| សមតុល្យចុងគ្រា/ឆ្នាំ | ១.៨៨៤.៥៣៦.៦១៥ | ១.៨៩៣.៨៦៤.៦១៩ |

* ចំនួនទាំងនេះតំណាងបុរេប្រទានផ្តល់ឱ្យអ្នកផ្គត់ផ្គង់ ដែលទាក់ទងនឹងការសាងសង់កំពុងដំណើរការ ដែលបានធ្វើមូលធនកម្មនៅការិយបរិច្ឆេទមុន ដែលការគ្រប់គ្រងលើទ្រព្យសម្បត្តិនោះមិនទាន់បានប្រគល់ជូន រ.ទ.ស.ភ នៅឡើយ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ គណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ បានកែចំណាត់ថ្នាក់លើបុរេប្រទានពីការសាងសង់កំពុងដំណើរការ ទៅក្នុងគណនីត្រូវទទួលផ្សេងៗ។

ក្នុងអំឡុងត្រីមាស និងសម្រាប់រយៈពេល៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ រ.ទ.ស.ភ បានធ្វើការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដោយទូទាត់ជាសាច់ប្រាក់ដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០២២<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ១៣១.៦៣៣.១២៦ | ១២១.៨៥៣.៨៩៧ |
| ទ្រព្យសកម្មផ្ទេរពីរោងចក្រផលិតទឹកស្អាតត្បូងឃ្មុំ | - | (៧៨.១៩២.២៦០) |
| មូលធនកម្មលើការប្រាក់លើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (១.០៧៨.៣១០) | (១.១៦៥.៩២៥) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ទូទាត់ជាសាច់ប្រាក់ | ១៣០.៥៥៤.៨១៦ | ៤២.៤៩៥.៧១២ |

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

### ៥. ទ្រព្យសកម្មកិច្ចសន្យា ឬ(បំណុលកិច្ចសន្យា)

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០២២<br>គិតជាពាន់រៀល | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **ទ្រព្យសកម្មកិច្ចសន្យា** | | |
| ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | ៣.០៥៣.១៣០ | ៥៣៦.០៥១ |
| ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងការលក់ទឹកស្អាត | ៦០.៣៣៧.៩៥២ | ៦៥.៤៨៨.៥២៩ |
| | ៦៣.៣៩១.០៨២ | ៦៦.០២៤.៥៨០ |
| **បំណុលកិច្ចសន្យា** | | |
| បំណុលកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | ១.៧៨៨.៨៩៤ | ១.៧៨៨.៨៩៤ |

### ៦. ការវិនិយោគរយៈពេលខ្លី

ចំនួនទាំងនេះតំណាងឱ្យប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់រយៈពេលចន្លោះពី ៩ ទៅ ១២ខែ (២០២១៖ ៩ ទៅ ១២ខែ) ហើយទទួលបានការប្រាក់ពី ៣,៥០% ទៅ ៤,៧៥% (២០២១៖ ៣,៥០% ទៅ ៤,៧៥%) ក្នុងមួយឆ្នាំ។

### ៧. ប្រាក់កម្ចី

| | រូបិយប័ណ្ណ | អត្រាការប្រាក់ធម្មតា | ឆ្នាំនៃកាលវសាន្ត | តម្លៃយោង |
|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ ២០២២** | | | | ៨១៣.៤៨៨.២៦៨ |
| **បោះផ្សាយថ្មី** | | | | |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៦ | | | | |
| ០១ S | ដុល្លារអាមេរិក | ០,៩០០% | ២០៣៨ | ១០.៧១៣.២១៧ |
| ធនាគារវិនិយោគអឺរ៉ុប ("EIB") | ដុល្លារអាមេរិក | ០,៦១០% - ០,៩៦៥% | ២០៤៨ | ១៣.៩២៨.៩២៥ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

### ៧. ប្រាក់កម្ចី (ត)

| | រូបិយប័ណ្ណ | អត្រាការប្រាក់ធម្មតា | ឆ្នាំនៃកាលវសាន្ត | តម្លៃយោង |
|---|---|---|---|---|
| **ទូទាត់សង** | | | | |
| ថ្លៃដើម | | | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | យ៉េន | ០,៦៦០% | ២០៤៩ | (៨០៨.៤៤៧) |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារអភិវឌ្ឍន៍អាស៊ី | SDR | ១,៦៥០% | ២០៣៧ | (១.១៤៨.៤២៧) |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | អឺរ៉ូ | ០,២៥០% | ២០២៥ | (៨.៨៦៥.២៨៥) |
| ការប្រាក់ | | | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | យ៉េន | ០,៦៦០% | ២០៤៩ | (១៤៥.៨៤៩) |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារអភិវឌ្ឍន៍អាស៊ី | SDR | ១,៦៥០% | ២០៣៧ | (២៩៣.៧១២) |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | អឺរ៉ូ | ០,២៥០% | ២០២៥ | (៧៧.៩៥៨) |
| **ការប្រាក់បង្គរ** | | | | ១.៨៩៦.៤៨៣ |
| **ចំណេញពិតពីការប្តូររូបិយប័ណ្ណ** | | | | (៤៣៧.៨១៥) |
| **ចំណេញមិនពិតពីការប្តូររូបិយប័ណ្ណ** | | | | (៨.៦០៤.០២៤) |
| **នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២** | | | | ៨១៩.៦៤៥.៣៧៦ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

## ៨. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០២២<br>គិតជាពាន់រៀល | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **រយៈពេលវែង៖** | | |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | ៧០.៨៩៥.៨០៦ | ៦៩.៩៤៦.០៧៣ |
| **រយៈពេលខ្លី៖** | | |
| **គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម** | | |
| ភាគីទីបី | ១៣២.៨៣៣.៨១៤ | ៣៣.២៥១.០៦៤ |
| ទឹកប្រាក់គ្រោងសម្រាប់ការងារកំពុងសាងសង់ | ២២.៥៨៤.៨៩៤ | ៣៨.២៨៣.០៩៩ |
| | ១៥៥.៤១៨.៧០៨ | ៧១.៥៣៤.១៦៣ |
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ** | | |
| ប្រាក់លើកទឹកចិត្តបុគ្គលិកបង្គរ | ២.៩៨៨.៣៧៨ | ៩.២៤១.២៣៧ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ៥៣.១៦៤.១៩៤ | ៤៧.៤៥៥.៩៥៨ |
| ប្រាក់ធានាប្រតិបត្តិការ | ៦៧.៣១៩ | ៦៧.៣៤៤ |
| ភាគលាភដែលត្រូវបង់ | ៤.០៤៤.២៥២ | - |
| ពន្ធត្រូវបង់ផ្សេងៗ | ១.៣៦២.៨៧៦ | ២៩៣.២៥៨ |
| ប្រាក់ជំពាក់បង្គរ | ៥.៩៧៧.១០៣ | ៦.១៤៦.០៧៦ |
| គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១៦.៣៩២.២៣២ | ៧.២៣១.៥០៩ |
| | ៨៣.៩៩៦.៣០៤ | ៧០.៤៣៥.៣៨២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ (រយៈពេលខ្លី) | ២៣៩.៤១៥.០១២ | ១៤១.៩៦៩.៥៤៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ (រយៈពេលវែង និងរយៈពេលខ្លី) | ៣១០.៣១០.៨១៨ | ២១១.៩១៥.៦១៨ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

## ៩. ចំណូលពីការលក់

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | **៣១ មីនា ២០២២** | **៣១ មីនា ២០២១** |
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ការលក់ទឹកស្អាត៖ | | |
| - អ្នកប្រើប្រាស់តាមផ្ទះ | ២៦.៤២០.០២៥ | ២៧.៩២៤.៦១៦ |
| - អ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ៣២.១៦៥.៧១៨ | ៣៣.៤៤៥.៣៤៧ |
| - ស្ថាប័នរដ្ឋបាលសាធារណៈ | ៤.៧៤១.២៦០ | ៤.២២៤.៣២៧ |
| - អ្នកបោះដុំ | ២.១៨៤.៧២៥ | ២.២៥៦.២០៤ |
| ភាពខុសគ្នានៃការបង្គត់លើប្រាក់ចំណូលពីការលក់ទឹកស្អាត | ១៦.១០៩ | ១៦.២០១ |
| ដក៖ ការលុបចោលវិក្កយបត្រ | (១០៤.២៧៦) | (១.៧៥៤.០៧៩) |
| | ៦៥.៤២៣.៥៦១ | ៦៦.១១២.៦១៦ |
| ចំណូលបានពីការភ្ជាប់បណ្តាញទឹកស្អាតតាមផ្ទះ | ២.៤២៣.៥៨៥ | ១.៤៩៦.០៧១ |
| ចំណូលការផ្លាស់ប្តូរនាឡិកាទឹក | ១.២២០.៨២៦ | ១.០៩៩.០៩១ |
| ការលក់គ្រឿងបន្លាស់ និងនាឡិកាទឹក | ៦៤.១៥៥ | ២១.២៨៥ |
| | ៦៩.១៣២.១២៧ | ៦៨.៧២៩.០៦៣ |

## ១០. ចំណូលការប្រាក់

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | **៣១ មីនា ២០២២** | **៣១ មីនា ២០២១** |
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ | ៨៦៤.៨៨៣ | ៤៦៣.៤៨៩ |
| ចំណូលមិនពិតពីការប្តូររូបិយប័ណ្ណប្រាក់កម្ចី | ៨.៦០៤.០២៤ | ៧.៦៦៩.២៥៣ |
| | ៩.៤៦៨.៩០៧ | ៨.១៣២.៧៤២ |

## ១១. ចំណាយការប្រាក់

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២២ | ៣១ មីនា ២០២១ |
| | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើប្រាក់កម្ចី | ១.៨៩៦.៤៨៣ | ១.៤៦៤.៧៨២ |
| ការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (១.០៧៨.៣១០) | (១.១៦៥.៩២៥) |
| | ៨១៨.១៧៣ | ២៩៨.៨៥៧ |

## ១២. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងទឹកប្រាក់ដែលបានគណនា ដោយយកប្រាក់ចំណេញមុនបង់ពន្ធសម្រាប់រយៈពេលរាយការណ៍ចន្លោះពេល គុណនឹងអត្រាពន្ធលើប្រាក់ចំណូលមធ្យមប្រចាំឆ្នាំដែលបានរំពឹងទុកសម្រាប់ពេញមួយឆ្នាំសារពើពន្ធ ដែលបានប៉ាន់ស្មានដ៏សមស្របបំផុតរបស់គណៈគ្រប់គ្រង ហើយធ្វើនិយ័តកម្មលើផលប៉ះពាល់ពន្ធលើឯកត្តាមួយចំនួន ដែលបានទទួលស្គាល់ទាំងស្រុងក្នុងគ្រា។ ដូច្នេះ អត្រាពន្ធប្រសិទ្ធភាពនៅក្នុងព័ត៌មានហិរញ្ញវត្ថុចន្លោះពេល អាចខុសគ្នាពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រងលើអត្រាពន្ធប្រសិទ្ធភាពសម្រាប់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

អត្រាពន្ធប្រសិទ្ធភាពរបស់ រ.ទ.ស.ភ សម្រាប់ត្រីមាស និងរយៈពេល៣ខែគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ នៃ២៦% គឺមិនមានបម្រែបម្រួលជាសារវន្តពីត្រីមាស និងរយៈពេល៣ខែគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ នៃ២៧%។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

## ១៣. ភាគលាភ

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | **៣១ មីនា ២០២២ គិតជាពាន់រៀល** | **៣១ មីនា ២០២១ គិតជាពាន់រៀល** |
| **ទទួលស្គាល់ក្នុងគ្រា** | | |
| ភាគលាភក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ តម្លៃ៣១០រៀល ក្នុងមួយភាគហ៊ុនធម្មតា* | ៤.០៤៤.២៥២ | - |
| ភាគលាភក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ តម្លៃ២៦២រៀល ក្នុងមួយភាគហ៊ុនធម្មតា | - | ២២.៧៨៦.៩៦៥ |

* នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានប្រកាស និងអនុម័តលើភាគលាភក្នុងតម្លៃ៣១០រៀល ក្នុងមួយភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ។

យោងតាមលិខិតអនុម័តពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ រ.ទ.ស.ភ ត្រូវបានលើកលែងលើការបង់ភាគលាភដោយ រ.ទ.ស.ភ ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រហូតដល់ការិយបរិច្ឆេទ ២០២៤ ហើយភាគលាភសម្រាប់ការិយបរិច្ឆេទ ២០២៥ នឹងត្រូវបានបន្តដូចតាមការអនុវត្តន៍ជាទូទៅរបស់ រ.ទ.ស.ភ។

ហេតុដូចច្នេះ ភាគលាភបានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទ គឺសម្រាប់ភាគហ៊ុនិកដទៃទៀតរបស់ រ.ទ.ស.ភ ក្នុងខណៈដែលចំណែកផ្នែករបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានផ្ទេរពីចំណេញរក្សាទុកទៅទុនបម្រុងសម្រាប់ការអភិវឌ្ឍន៍របស់ រ.ទ.ស.ភ ដោយផ្ទាល់។

## ១៤. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖

(ក) ស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ

សាជីវកម្មដែលភ្ជាប់ទៅនឹងរាជរដ្ឋាភិបាល គឺមានពាក់ព័ន្ធជាមួយ រ.ទ.ស.ភ ដែលត្រូវបានកាន់កាប់ភាគហ៊ុនដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នដែលគ្រប់គ្រងដោយផ្ទាល់ដោយរាជរដ្ឋាភិបាលត្រូវបានសំដៅទាំងស្រុងជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹង រ.ទ.ស.ភ។

រាជរដ្ឋាភិបាល និងស្ថាប័នដែលគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាភាគីពាក់ព័ន្ធជាមួយនឹង រ.ទ.ស.ភ។ រ.ទ.ស.ភ បានធ្វើប្រតិបត្តិការជាមួយស្ថាប័នជាច្រើនដែលរួមមានមិនត្រឹមតែការទិញទំនិញប៉ុណ្ណោះទេ ថែមទាំងរួមមានការប្រើប្រាស់ទឹកជាសាធារណៈ និងការដាក់ប្រាក់បញ្ញើ។

រាល់ប្រតិបត្តិការទាំងអស់ដែលបានកត់ត្រាដោយ រ.ទ.ស.ភ ជាមួយស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ គឺត្រូវបានធ្វើឡើងក្នុងសកម្មភាពអាជីវកម្មធម្មតារបស់ រ.ទ.ស.ភ ស្តីពីលក្ខខ័ណ្ឌធរតា ឬលក្ខខ័ណ្ឌប្រហាក់ប្រហែលនឹង ស្ថាប័នផ្សេងទៀត ដែលមិនមែនជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធលើកលែងតែមានការបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

រ.ទ.ស.ភ បានរួមចំណែកយ៉ាងសំខាន់នៅក្នុងដំណើរការផលិត និងការចែកចាយទឹកដែលជាផ្នែកមួយនៃប្រតិបត្តិការធម្មតារបស់ខ្លួន។ សេវាកម្មទាំងនេះត្រូវបានអនុវត្តជាប្រចាំ លើលក្ខខ័ណ្ឌពាណិជ្ជកម្មដែលត្រូវបានអនុវត្តជាមួយអតិថិជនទាំងអស់។ ប្រតិបត្តិការទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើលក្ខខ័ណ្ឌដែលមិនខុសគ្នាជាសារវន្តពីប្រតិបត្តិការជាមួយភាគីដែលមិនពាក់ព័ន្ធគ្នា។

ក្រៅពីប្រតិបត្តិការ និងសមតុល្យសំខាន់ៗនីមួយៗ ដូចបានបង្ហាញនៅកន្លែងណាមួយនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាសមូហភាព ប៉ុន្តែមិនមានប្រតិបត្តិការទោលសំខាន់ជាមួយភាគីពាក់ព័ន្ធទេ។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)**

## ១៤. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

(ខ) លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗ

លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗសរុបត្រូវបានវិភាគដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២២ គិតជាពាន់រៀល | ៣១ មីនា ២០២១ គិតជាពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ៥៤៥.០០១ | ៥៦៦.៤២០ |

## ១៥. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលដៅនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គឺដើម្បីបង្កើនតម្លៃជាអតិបរមាសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះ កាត់បន្ថយសក្តានុពលជាអប្បបរមានៃផលប៉ះពាល់មិនល្អដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់គោលដៅទាំងនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ។ ហេតុនេះ គណៈគ្រប់គ្រងបានបង្កើតគោលការណ៍លម្អិតដូចជាកម្រិតនៃសិទ្ធិអំណាច ការទទួលខុសត្រូវលើការត្រួតពិនិត្យ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ដោយអនុលោមតាមគោលដៅ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

(ក) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍របស់ រ.ទ.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថា រ.ទ.ស.ភ ប្រឈមនិងហានិភ័យឥណទានតិចបំផុត។

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)**

**១៥. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

(ក) ហានិភ័យឥណទាន (ត)

ហានិភ័យឥណទានដែល រ.ទ.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីអតិថិជនពាណិជ្ជកម្ម ដែលត្រូវទទួលពីអតិថិជន។ រយៈពេលឥណទានមានចំនួនមួយខែ ហើយ រ.ទ.ស.ភ ព្យាយាមធ្វើការគ្រប់គ្រងយ៉ាងជិតដល់ លើគណនីត្រូវទទួលដែលមិនទាន់ប្រមូលបាន ដើម្បីកាត់បន្ថយហានិភ័យឥណទានអោយបានទាបបំផុត។ សមតុល្យដែលហួសកំណត់ត្រូវបានត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង។

(ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ រ.ទ.ស.ភ ទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល រ.ទ.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

រ.ទ.ស.ភ គ្រប់គ្រងទិន្នន័យកាលវសានរបស់បំណុល លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ ការវិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល រ.ទ.ស.ភ ធ្វើការរក្សានូវកម្រិតសាច់ប្រាក់និងសាច់ប្រាក់សមមូល គ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ។

(គ) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងប្រែប្រួល ដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

## ១៥. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(គ) ហានិភ័យអត្រាការប្រាក់ (ត)

ការប្រឈមរបស់ រ.ទ.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ ទាក់ទងនឹងកម្ចីជាចម្បង។ រ.ទ.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើទីផ្សារបំណុល ហើយសំខាន់ជាងនេះទៀត គឺរក្សាអោយបានការលាយឡំគ្នារបស់អត្រាការប្រាក់ថេរ និងអត្រាការប្រាក់អថេររបស់កម្ចីដោយប្រុងប្រយ័ត្ន។ រ.ទ.ស.ភ ពុំបានប្រើប្រាស់ ដេរីវេទីវឧបករណ៍ហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

(ឃ) តម្លៃសមស្រប

តារាងខាងក្រោមបង្ហាញពីតម្លៃយោង និងតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ វាមិនរាប់បញ្ចូលព័ត៌មានអំពី តម្លៃសមស្របសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានវាស់វែងតាមវិធីសាស្ត្រតម្លៃសមស្របទេ ប្រសិនបើតម្លៃយោង គឺជាការប៉ាន់ប្រមាណសមហេតុផលនៃតម្លៃសមស្រប។

គណនីអតិថិជនពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ ទ្រព្យសកម្មកិច្ចសន្យា ឥណទានផ្តល់ឱ្យបុគ្គលិក ការវិនិយោគរយៈពេលខ្លី សាច់ប្រាក់ និងសាច់ប្រាក់សមមូល គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជ និងគណនីត្រូវបង់ផ្សេងៗ បំណុលកិច្ចសន្យា មិនត្រូវបានបញ្ចូលក្នុងតារាងខាងក្រោមទេ។ តម្លៃយោងទាំងនេះ គឺជាការប៉ាន់ប្រមាណសមហេតុផលនៃតម្លៃសមស្រប។

| | តម្លៃយោង គិតជាពាន់រៀល | តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុមិនប្រើប្រាស់វិធីសាស្ត្រតម្លៃសមរម្យ គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចី** | | |
| ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ | ៨១៩.៦៤៥.៣៧៦ | ៨២៧.៦៧៩.២៣២ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៨១៣.៤៨៨.២៦៨ | ៨២១.៤៤៦.២៣៨ |

### ១៥. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(ឃ) តម្លៃសមស្រប (ត)

**តម្លៃសមស្រប កម្រិតទី៣**

<u>តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុមិនប្រើប្រាស់វិធីសាស្ត្រតម្លៃសមរម្យ</u>

តម្លៃសមស្របនៃប្រាក់កម្ចី ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រអប្បហារលំហូរសាច់ប្រាក់ ដោយផ្អែកលើអត្រាអប្បហារ ដែលឆ្លុះបញ្ចាំងអំពីអត្រាកម្ចីរបស់អ្នកបោះផ្សាយនៅចុងគ្រារាយការណ៍។

### ១៦. ចំណាយជាប់កិច្ចសន្យា

នៅចុងត្រីមាសនៃការិយបរិច្ឆេទនេះ រ.ទ.ស.ភ បានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនទៅលើទ្រព្យសកម្មដូចខាងក្រោម៖

| | **មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី** | |
|---|---|---|
| | **៣១ មីនា ២០២២** | **៣១ មីនា ២០២១** |
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ២៨៨.៨៩៧.៩៧៤ | ៥១៨.៨៩៤.៤៧១ |
| សេវាផ្តល់ការប្រឹក្សាយោបល់ | ៦.៧៥០.៣២៩ | ៩.៧៦៣.២២២ |
| ការទិញបំពង់ដែកស្ទិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ១.៩០៨.២២៧ | ១៤១.០៦៨.២៦៨ |
| | ២៩៧.៥៥៦.៥៣០ | ៦៦៩.៧២៥.៩៦១ |

### ១៧. ព័ត៌មានតាមផ្នែក

ព័ត៌មានតាមផ្នែកមិនបានបង្ហាញ ដោយសារ រ.ទ.ស.ភ បានពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងដំណើរការ និងការចែកចាយទឹក សម្រាប់ប្រើប្រាស់ជាទូទៅ ដល់សាធារណជននៅក្នុងរាជធានីភ្នំពេញ និងការផ្តល់សេវាកម្មពាក់ព័ន្ធផ្សេងៗ ដែលស្ថិតនៅក្នុងផ្នែកអាជីវកម្មតែមួយ និងមានសង្គតិភាពស្របនឹងការអនុវត្តបច្ចុប្បន្ននៃរបាយការណ៍ផ្ទៃក្នុង។ រ.ទ.ស.ភ ធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ (ត)

## ១៨. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងឆ្នាំហិរញ្ញវត្ថុ

នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ រ.ទ.ស.ភ បានធ្វើការប្រកាសតាមរយៈ ផ្សារមូលបត្រកម្ពុជា សេចក្ដីប្រកាសនេះមានដូចតទៅ៖

*"រ.ទ.ស.ភ មានសេចក្តីសោមនស្សសូមជំរាបជូនដល់វិនិយោគិន និងសាធារណជនជ្រាបថា នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ នៅទីស្នាក់ការកណ្តាលរបស់ រ.ទ.ស.ភ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អ៊ុំ សុថា ប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាគម្រោងស្តីពី ការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្រុងតាខ្មៅ រវាង រ.ទ.ស.ភ និង KKKCT Consortium ដែលជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។"*

*គម្រោងប្រភេទនេះសម្រាប់ការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត គឺជាគម្រោង Special Purpose Company (SPC) លក់ជាដុំជូន រ.ទ.ស.ភ ក្នុងតម្លៃតូចជាង ឬមិនឱ្យលើសពី ៥០០រៀល/ម៉ែ ដែលមានរយៈពេល ១០ឆ្នាំ (២០២៤ - ២០៣៤)។ គម្រោងនេះនឹងផ្តើមដំណើរការសាងសង់នាខែមិថុនា ឆ្នាំ២០២២ និងបញ្ចប់នាខែធ្នូ ឆ្នាំ២០២៤ ក្រោមការគ្រប់គ្រងរបស់ KKKCT CONSORTIUM CONSTRUCTION និង CONSORTIUM OF NIHON SUIDO CONSTRUCTIONS CO., LTD. និង CROWN AGENTS JAPAN LIMITED ទីប្រឹក្សាបច្ចេកទេសមកពីប្រទេសជប៉ុន។"*

## ១៩. តួលេខប្រៀបធៀប

តួលេខប្រៀបធៀបជាក់លាក់ត្រូវបានចាត់ថ្នាក់ឡើងវិញ ដើម្បីអនុលោមតាមការបង្ហាញនៃពេលបច្ចុប្បន្ន។

## ២០. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនសម្រាប់ត្រីមាស និងរយៈពេល៣ខែគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ ស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី ខែ ឆ្នាំ។

លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

## របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ជូនចំពោះសមាជិកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា "រ.ទ.ស.ភ" នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ព្រមទាំងរបាយការណ៍ប្រាក់ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេលសម្រាប់រយៈពេល៣ខែ និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលពាក់ព័ន្ធ (ត្រូវបានគេស្គាល់ថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ")។ ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញភាពសមស្របនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់យើងខ្ញុំ។

### វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាមស្តង់ដារអន្តរជាតិលើការត្រួតពិនិត្យ លេខ ២៤១០ ស្តីពី *ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការអនុវត្តនូវការវិភាគ និងនិតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងកំណត់បានប្រសិនបើធ្វើសវនកម្ម។ ដូច្នេះយើងខ្ញុំមិនអាចបញ្ចេញមតិយោបល់សវនកម្មនោះទេ។

bakertilly

លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**ជូនចំពោះសមាជិកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**សេចក្តីសន្និដ្ឋាន**

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ ដែលបានភ្ជាប់មកជាមួយនេះមិនបានបង្ហាញនូវភាពសមស្របគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ មិនស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

ព្រះរាជាណាចក្រកម្ពុជា
ប្រ៊ូមហ៊ុន
បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក
BAKER TILLY (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

| | |
|---|---|
| **បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក** | Tan Khee Meng |
| គណនេយ្យករជំនាញ | គណនេយ្យករជំនាញ |

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 09 JUN 2022

# ផ្នែកទី៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

រ.ទ.ស.ភ មានចំណូល៣ប្រភេទធំៗគឺចំណូលបានមកពីការលក់ទឹក សេវាសាងសង់ និងចំណូលផ្សេងៗ៖

- ចំណូលបានមកពីការលក់ទឹករួមមាន:ចំណូលពីការប្រើប្រាស់ប្រភេទជីវភាពអាជីវកម្ម ឧស្សាហកម្ម អង្គភាពរដ្ឋ បន្ទប់ជួល និងអ្នកលក់ទឹកបន្ត។ ចំណូលទាំងនេះត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយការកាត់កងជាមួយអប្បហារវិភាជន៍ និងឥណទានហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹកដែលបានផ្គត់ផ្គង់ជូនអតិថិជនរបស់ខ្លួន។ ការធ្វើវិក្កយបត្រនៃការប្រើប្រាស់ទឹក ត្រូវបានធ្វើឡើងក្នុងរយៈពេលរៀងរាល់២ខែម្តង។

- ចំណូលបានពីសេវាសាងសង់: គឺជាចំណូលបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹក ដែល រ.ទ.ស.ភ បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។

- ចំណូលផ្សេងៗរួមមាន: ចំណូលបានមកពីការថែទាំនាឡិកា លក់សម្ភារតបណ្តាញទឹក ការផាកពិន័យលើការប្រើប្រាស់ទឹកពុំមានការអនុញ្ញាតពី រ.ទ.ស.ភ និងផ្សេងៗ។

- **ចំណូលថែទាំនាឡិកា៖** គឺចំណូលបានពីថ្លៃឈ្នួលថែទាំនាឡិកាដោយគិតថ្លៃ៥០រៀលក្នុង១មីលីម៉ែត្រក្នុងមួយខែ នៃទំហំនាឡិកាទឹកក្នុងអំឡុងវដ្តនៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល។ ចំណូលនេះ ត្រូវបានប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនាឡិកាជូនអតិថិជននាពេលអនាគត។
- **ចំណូលពីការលក់សម្ភារតបណ្តាញទឹក៖** គឺជាចំណូលទទួលបានពីការលក់នាឡិកាស្ទង់ទឹក បំពង់ និងសម្ភារតភ្ជាប់។
- **ចំណូលពីការផាកពិន័យ៖** គឺជាចំណូលទទួលបានពីការផាកពិន័យលើការបង់ថ្លៃប្រើប្រាស់ទឹកយឺតយ៉ាវ និងពិន័យលើបទល្មើសតបណ្តាញទឹកដោយពុំមានការអនុញ្ញាតពី រ.ទ.ស.ភ.។
- **ចំណូលផ្សេងៗ៖** គឺជាចំណូលទទួលបានមកពីការរួមចំណែករបស់អតិថិជនប្រភេទពាណិជ្ជកម្ម និងឧស្សាហកម្មក្នុងការវិនិយោគសម្រាប់ការភ្ជាប់បណ្តាញពិសេសចូលទីតាំងផ្ទាល់របស់ពួកគេ។ ក្រៅពីនោះគឺជាចំណូលដែលទទួលបានពីកម្រៃសេវាលើការទារថ្លៃថែទាំលូទឹកស្អុយរបស់សាលារាជធានីភ្នំពេញ។

➢**ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១**

| បរិយាយ | ត្រីមាសទី១ ឆ្នាំ២០២២ (ពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល(ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ៨២.០២០.០១០ | ៨៤.៣០៤.៧២៦ | (២.២៨៤.៧១៦) | (២.៧១) |

រ.ទ.ស.ភ. មានចំណូលសរុប ៨២.០២០.០១០.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង ៨៤.៣០៤.៧២៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ២.២៨៤.៧១៦.០០០រៀល ស្មើនឹង២,៧១%។ យើងបានឃើញថាកត្តាចម្បងនៃការថយចុះ នៃចំណូលនេះគឺដោយសារចំណូលពីសេវាសាងសង់ក្នុងត្រីមាសទី១ឆ្នាំ២០២២នេះមានការថយចុះប្រមាណ ៤៥,២៣% ដែលស្មើនឹងទឹកប្រាក់ចំនួន ៣.១៥១.៧៨៥.០០០រៀល ដោយឡែកចំណូលផ្សេងៗមានកំណើនប្រមាណ ១២,៥០% ស្មើនឹងទឹកប្រាក់ចំនួន ១.០០៧.៦៣១.០០០រៀល។

### ២- ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់ រ.ទ.ស.ភ មានដូចខាងក្រោម:

| បរិយាយ | ត្រីមាសទី១ ឆ្នាំ២០២២ (ពាន់រៀល) | | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | |
|---|---|---|---|---|
| ចំណូលថ្លៃលក់ទឹក | ៦៩.១៣២.១២៧ | ៨៤,២៩ | ៦៨.៧២៩.០៦៣ | ៨១,៥២ |
| ចំណូលពីសេវាសាងសង់ | ៣.៨១៦.៥៥៧ | ៤,៦៥ | ៦.៩៦៨.៣៤២ | ៨,២៧ |
| ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | - | - | ៥៤៣.៦២៦ | ០,៦៤ |
| ចំណូលផ្សេងៗ | ៩.០៧១.៣២៦ | ១១,០៦ | ៨.០៦៣.៦៩៥ | ៩,៥៦ |

# ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ២- ការវិភាគចំណូលតាមផ្នែក (ត)

មានតែប្រាក់ចំណូលតាមប្រភេទជាសារវន្តត្រូវបានលើកឡើងសម្រាប់ការវិភាគខាងក្រោម៖

➢**ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១**

| បរិយាយ | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | | បម្រែបម្រួល | | |
|---|---|---|---|---|---|---|---|
| | បរិមាណ ម$^{៣}$/បណ | ទឹកប្រាក់ ពាន់រៀល | បរិមាណ ម$^{៣}$/បណ | ទឹកប្រាក់ ពាន់រៀល | បរិមាណ ម$^{៣}$/បណ | ទឹកប្រាក់ ពាន់រៀល | ភាគរយ |
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ | ២៧.១៨៨.៦២០ | ២៦.៤២០.០២៥ | ២៧.៣០១.៩២០ | ២៧.៩២៤.៦១៦ | (១១៣.៣០០) | (១.៥០៤.៥៩១) | (៥,៣៩%) |
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ១៩.៥៤៦.៩៣១ | ៣២.១៦៥.៧១៨ | ១៩.៣៦២.៥៣៩ | ៣៣.៤៤៥.៣៤៧ | ១៨៤.៣៩២ | (១.២៧៩.៦២៩) | (៣,៨៣%) |
| ការលក់ទឹកជូនគ្រឹះស្ថានសាធារណៈ | ១.៨៤៧.២៣១ | ៤.៦១៨.០៧៨ | ១.៦៤១.៣៩០ | ៤.១០៣.៤៧៦ | ២០៥.៨៤១ | ៥១៤.៦០២ | ១២,៥៤% |
| ការលក់ទឹកស្អាតជូនតំណាងចែកចាយ និងបន្ទប់ជួល | ២.៨៦៧.៤០៥ | ២.១៨៤.៧២៥ | ៣.០៨១.១៩២ | ២.២៥៦.២០៤ | (២១៣.៧៨៧) | (៧១.៤៧៩) | (៣,១៧%) |

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ (ប្រភេទជីវភាព)**

រ.ទ.ស.ភ មានចំណូលថ្លៃលក់ទឹក ប្រភេទជីវភាព បានចំនួន ២៦.៤២០.០២៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង ២៧.៩២៤.៦១៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ១.៥០៤.៥៩១.០០០រៀល ស្មើនឹង ៥,៣៩%។ យើងឃើញថាការថយចុះនេះដោយសារបរិមាណប្រើប្រាស់ទឹកក្នុង១បណ្តាញក្នុង១ខែបានថយចុះចំនួន ០,៧៩ម$^{៣}$ ពី ២៤,៩៨ម$^{៣}$ មកត្រឹម ២៤,១៩ម$^{៣}$ ហើយថ្លៃលក់ទឹកមធ្យមក៏បាន ថយចុះចំនួន ៥១,០៨រៀល/ម$^{៣}$ ពី ១.០២២,៨១រៀល/ម$^{៣}$ មកត្រឹម ៩៧១,៧៣រៀល/ម$^{៣}$។

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម (ប្រភេទអាជីវកម្ម និងឧស្សាហកម្ម)**

រ.ទ.ស.ភ មានចំណូលថ្លៃទឹកប្រភេទអាជីវកម្ម និងឧស្សាហកម្មចំនួន ៣២.១៦៥.៧១៨.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង ៣៣.៤៤៥.៣៤៧.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ១.២៧៩.៦២៩.០០០រៀល ស្មើនឹង ៣,៨៣%។ យើងឃើញថាការថយចុះនេះដោយសារបរិមាណប្រើប្រាស់ទឹកក្នុង១បណ្តាញក្នុង១ខែបានថយចុះចំនួន ២,១៤ម$^{៣}$ ពី ៩២,៩៥ម$^{៣}$ មកត្រឹម ៩០,៨១ម$^{៣}$ ហើយថ្លៃលក់ទឹកមធ្យមក៏បានថយចុះចំនួន ៨១,៧៦រៀល/ម$^{៣}$ ពី ១.៧២៧,៣២រៀល/ម$^{៣}$ មកត្រឹម ១.៦៤៥,៥៦រៀល/ម$^{៣}$។

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់គ្រឹះស្ថានសាធារណៈ**

រ.ទ.ស.ភ មានចំណូលថ្លៃលក់ទឹកប្រភេទគ្រឹះស្ថានសាធារណៈចំនួន ៤.៦១៨.០៧៨.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង ៤.១០៣.៤៧៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់កើនឡើងចំនួន ៥១៤.៦០២.០០០រៀល ស្មើនឹង ១២,៥៤% ។ ការកើនឡើងនេះដោយសារចំនួនអតិថិជនបានកើនឡើងចំនួន ១០៤បណ្តាញពី ៧៧៤បណ្តាញ ដល់ ៨៧៨បណ្តាញ ដោយឡែកបរិមាណប្រើប្រាស់ទឹកក្នុង១បណ្តាញក្នុង១ខែបានថយចុះចំនួន៧៥,០៦ម$^{៣}$ ពី៩០១,១០ម$^{៣}$ មកត្រឹម៨២៦,០៤ម$^{៣}$ ។

- **ចំណូលបានពីការលក់ទឹកស្អាតជូនតំណាងចែកចាយ និងបន្ទប់ជួល**

រ.ទ.ស.ភ. មានចំណូលពីការលក់ទឹកស្អាតជូនបន្ទប់ជួលចំនួន ២.១៨៤.៧២៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង២.២៥៦.២០៤.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ខែមីនា ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ៧១.៤៧៩.០០០រៀល ស្មើនឹង៣,១៧%។ យើងឃើញថាការថយចុះនេះ

ដោយសារបរិមាណប្រើប្រាស់ទឹកក្នុងមួយបណ្តាញក្នុងមួយខែ បានថយចុះ ៧,២០ម៣ ពី ១៧៣,១៦ម៣ មកត្រឹម ១៦៥,៩៦ម៣ ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៣-ការវិភាគគម្លាតចំណេញដុល

រ.ទ.ស.ភ បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទ ដូចនេះពុំមានការបង្ហាញ ឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការ ដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តិបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី ៤- ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធខាងក្រោម។

### ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និង ចំណូល (ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សា និងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកចំណាយរំលស់ ទ្រព្យសកម្មរូបីនិងអរូបី ចំណាយលើការប្រើប្រាស់អគ្គិសនី និងចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល ចំណាយវត្ថុធាតុដើមសម្រាប់ប្រព្រឹត្តកម្មទឹកស្អាត ចំណាយសេវាសាងសង់ ចំណូល (ចំណាយ)ការប្រាក់ យកមកពិភាក្សាដូចខាងក្រោម៖

- **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១**

| បរិយាយ | ត្រីមាសទី១ឆ្នាំ២០២២ (ពាន់រៀល) | ត្រីមាសទី១ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ៨២.០២០.០១០ | ៨៤.៣០៤.៧២៦ | (២.២៨៤.៧១៦) | (២,៧១%) |
| ចំណាយរំលស់លើ ទ្រព្យសកម្មរូបី និងអរូបី | (១៤.៨៧៨.៨៣៨) | (១២.៦២០.៩៨៥) | (២.២៥៧.៨៥៣) | (១៧,៨៩%) |
| ចំណាយការប្រើប្រាស់អគ្គិសនី | (៨.៥២៣.៦៥៩) | (៨.៩៤៦.៧៩៤) | ៤២៣.១៣៥ | ៤,៧៣% |
| ចំណាយប្រាក់បៀវត្សរ៍ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (១៦.០៥៤.៤៦៨) | (១៤.៦៨៥.៩៩២) | (១.៣៦៨.៤៧៦) | (៩,៣២%) |
| ចំណាយវត្ថុធាតុដើមសម្រាប់ ផលិតទឹកស្អាត | (២.៥៧៩.៩៩៣) | (២.៩១២.៥៨៨) | ៣៣២.៥៩៥ | ១១,៤២% |
| ចំណាយសេវាសាងសង់ | (១.៩៩១.០២៨) | (៦.៥០៧.៣៥០) | ៤.៥១៦.៣២២ | ៦៩,៤០% |
| ចំណូលការប្រាក់ | ៩.៤៦៨.៩០៧ | ៨.១៣២.៧៤២ | ១.៣៣៦.១៦៥ | (១៦,៤៣%) |
| ចំណាយការប្រាក់ | (៨១៨.១៧៣) | (២៩៨.៨៥៧) | (៥១៩.៣១៦) | (១៧៣,៧៧%) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | **៤០.៦៨៦.២៦៩** | **៤២.៤១៦.០៣៩** | **(១.៧២៩.៧៧០)** | **(៤.០៨%)** |

រ.ទ.ស.ភ មានចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួន ៤០.៦៨៦.២៦៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង ៤២.៤១៦.០៣៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ១.៧២៩.៧៧០.០០០រៀល ស្មើនឹង៤.០៨%។ យើងឃើញថាកត្តាចម្បងនៃការថយចុះនេះគឺ ដោយសារចំណូលសរុបបានថយចុះចំនួន ២.២៨៤.៧១៦.០០០រៀល ស្មើនឹង២,៧១ % ចំណាយរំលោះបានកើនឡើងប្រមាណចំនួន ២.២៥៧.៨៥៣.០០០រៀល ស្មើនឹង១៧,៨៩% ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ បានកើនឡើងប្រមាណ ១.៣៦៨.៤៧៦.០០០ ស្មើនឹង៩,៣២% ចំណាយវត្ថុធាតុដើមថយចុះ ៣៣២.៥៩៥.០០០រៀល ស្មើនឹង ១១.៤២%។ ដោយឡែកចំណាយសេវាសាងសង់មានការថយចុះប្រមាណ ៤.៥១៦.៣២២.០០០រៀល ស្មើនឹង៦៩,៤០% ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

រ.ទ.ស.ភ ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ចត្រូវបង់ពន្ធ លើប្រាក់ចំណេញអត្រា ២០%។ ដោយឡែកពន្ធលើប្រាក់ចំណេញដែលជាប់អត្រា ២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យ ទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ ២០%។

- **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១**

| បរិយាយ | ត្រីមាសទី១ឆ្នាំ២០២២ (ពាន់រៀល) | ត្រីមាសទី១ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ (ក) | ៤០.៦៨៦.២៦៩ | ៤២.៤១៦.០៣៩ | (១.៧២៩.៧៧០) | (៤.០៨%) |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (១០.៣៩៤.៥២០) | (១១.៦៤៤.៤៣០) | ១.២៤៩.៩១០ | (១០,៧៣%) |
| ចំណេញក្នុងការិយបរិច្ឆេទ | ៣០.២៩១.៧៤៩ | ៣០.៧៧១.៦០៩ | ៤៧៩.៨៦០ | (១.៥៦%) |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៣០.២៩១.៧៤៩ | ៣០.៧៧១.៦០៩ | ៤៧៩.៨៦០ | (១.៥៦%) |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ២៥,៥៥% | ២៧,៤៥% | | |

រ.ទ.ស.ភ មានចំណេញក្នុងការិយបរិច្ឆេទចំនួន ៣០.២៩១.៧៤៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និង ៣០.៧៧១.៦០៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលទឹកប្រាក់នេះមានការថយចុះចំនួន ៤៧៩.៨៦០.០០០រៀល ស្មើនឹង១,៥៦%។ ការថយចុះនេះដោយសារប្រាក់ចំណេញមុនបង់ពន្ធបានថយចុះចំនួន ១.៧២៩.៧៧០.០០០រៀល ស្មើនឹង ៤,០៨%។

### ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ទោះបីផលចំណេញដែលទទួលបានក្នុងត្រីមាសទី១ឆ្នាំ២០២២ ទាបជាងត្រីមាសទី១ឆ្នាំ២០២១ ដោយសារចំណូលសេវាសាងសង់ថយចុះក៏ដោយ ក៏ស្ថានភាពចំណូលថ្លៃលក់ទឹកនិងចំណូលផ្សេងៗនៅតែមានកំណើនពីមួយត្រីមាសទៅមួយត្រីមាសផងដែរ គឺដោយសារតែមានកត្តាគាំទ្រ ដូចខាងក្រោម៖

- អត្រាទឹកបាត់បង់៖ រ.ទ.ស.ភ បានប្រើប្រាស់នូវយន្តការដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាទឹកបាត់បង់ មកត្រឹម៨,៦៤% ប៉ុណ្ណោះនៅត្រីមាសទី១ឆ្នាំ២០២២នេះ។ នេះជាកត្តាចម្បងដែលធ្វើឲ្យ រ.ទ.ស.ភ មានចេរភាពហិរញ្ញវត្ថុ និងអភិវឌ្ឍ សហគ្រាសរក្សានូវស្ថានភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសហគ្រាសប្រកបដោយនិរន្តភាព។

- ការបង្កើនចំនួនអតិថិជន៖ ដើម្បីទទួលបាននូវចំណូលពីការលក់ទឹកស្អាត រ.ទ.ស.ភ. បានបង្កើនចំនួនអតិថិជន របស់ខ្លួន ដោយពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតទៅតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដូចជាការបំពេញ ផ្ទៃសេវាឲ្យបាន ១០០% នៅក្នុងរាជធានីភ្នំពេញ តំបន់ជុំវិញរាជធានីភ្នំពេញ ជាពិសេសតំបន់ដែលមានសក្តានុពល សេដ្ឋកិច្ច។

- ការបង្កើនថ្លៃលក់ទឹកមធ្យម៖ តាមរយៈការស្វែងរកអតិថិជន ដែលជាប្រភេទអាជីវកម្ម-ឧស្សាហកម្ម ធ្វើឲ្យថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ កើនឡើងដោយសារតែថ្លៃប្រើប្រាស់ទឹករបស់អតិថិជនប្រភេទនេះមានកម្រិត ខ្ពស់ជាងអតិថិជនប្រភេទ ផ្សេងទៀត។

- ការគ្រប់គ្រងលើការចំណាយប្រតិបត្តិការ៖ រ.ទ.ស.ភ ធ្វើការគ្រប់គ្រងលើការចំណាយនេះ ពិសេសការចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនីដែលជាចំណាយដ៏ធំ និងសំខាន់ក្នុងដំណើរការប្រព្រឹត្តកម្មទឹកស្អាត តាមរយៈការប្រើប្រាស់នូវ បច្ចេកវិទ្យាថ្មីៗ ដូចជាជ្រើសរើសយកការប្រើប្រាស់ម៉ាស៊ីនបូមទឹកដែលអាចប្រែប្រួលទៅតាមសំពាធទឹក ក៏ដូចជាការចាត់ចែងការប្រើប្រាស់នូវវត្ថុធាតុដើមក្នុងប្រព្រឹត្តកម្មទឹកប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់។

ចំពោះការចំណាយដំណើរការសហគ្រាស រ.ទ.ស.ភ ក៏បានខិតខំកាត់បន្ថយនូវការចំណាយដែលមិនចាំបាច់ ដូចជាចំណាយរដ្ឋបាលទូទៅ ចំណាយលើការជួសជុលថែទាំទូទៅ ដែលអង្គភាពបានយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យ និងថែទាំឧបករណ៍បរិក្ខាប្រើប្រាស់ជាប្រចាំ ដើម្បីធានាបានគុណភាពប្រើប្រាស់ និងកាត់បន្ថយការចំណាយជួសជុលនានា។

- ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវដំណើរការកិច្ចលទ្ធកម្ម៖ រ.ទ.ស.ភ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់បញ្ញត្តិ និងគោលការណ៍ ណែនាំផ្សេងៗសម្រាប់ដំណើរការកិច្ចលទ្ធកម្មក្នុងការទិញសម្ភារ បរិក្ខា និងវត្ថុធាតុដើម ដែលដំណើរការនេះឆ្លុះបញ្ចាំងឱ្យឃើញពី តម្លាភាព និងការប្រកួតប្រជែងថ្លៃទំនិញនៅលើទីផ្សារ ដែលជាហេតុធ្វើឲ្យ រ.ទ.ស.ភ. ទទួលបានការទិញទំនិញមានតម្លៃសមរម្យ គុណភាពអាចទទួលយកបាន។

- ការគ្រប់គ្រងសាច់ប្រាក់៖ តាមរយៈអត្រាទារប្រាក់ដែលមានកម្រិតខ្ពស់៩៩.៩០% បានធ្វើឲ្យ រ.ទ.ស.ភ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្នុងការគ្រប់គ្រង រ.ទ.ស.ភ បានរក្សាទុកនូវសាច់ប្រាក់សម្រាប់ប្រើប្រាស់ជាទុនបង្វិលក្នុងរយៈពេល ២ទៅ៣ខែ ឯសាច់ប្រាក់ដែលទំនេរពុំមានតម្រូវការប្រើប្រាស់ រ.ទ.ស.ភ បានធ្វើការវិនិយោគរយៈពេលខ្លី ដោយដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លីនៅធនាគារពាណិជ្ជជាមួយនឹងការទទួលបាននូវអត្រាការប្រាក់ខ្ពស់ ប៉ុន្តែ រ.ទ.ស.ភ ក៏បានធ្វើការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញពីអត្រាការប្រាក់ខ្ពស់នេះផងដែរ។

- ការជ្រើសរើសយកនូវអ្នកផ្តល់ហិរញ្ញប្បទានដែលផ្តល់អត្រាការប្រាក់ទាប៖ ដោយសារមានតម្រូវការ ប្រើប្រាស់ទឹកស្អាត កើនឡើងខ្ពស់ ធ្វើឲ្យ រ.ទ.ស.ភ មានតម្រូវការហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគដូចជាការ សាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាត ការតបណ្តាញមេនាំទឹក និងបណ្តាញចែកចាយ។ រ.ទ.ស.ភ បានស្វែងរកដៃគូ អភិវឌ្ឍអន្តរជាតិដូចជាទីភ្នាក់ងារបារាំង សម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីទទួលបាននូវហិរញ្ញប្បទាន ដែលមានអត្រាការប្រាក់ទាប។

- ស្ថានភាពសេដ្ឋកិច្ច៖ ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ជាសកលនៅតែបន្ត និងការប្រែប្រួលនូវស្ថានភាពសេដ្ឋកិច្ចបានជះឥទ្ធិពលលើមធ្យមភាគនៃការប្រើប្រាស់ទឹកក្នុងមួយបណ្តាញក្នុងមួយខែ ដែលធ្វើឲ្យមានការប្រែប្រួលទៅលើថ្លៃលក់ទឹកមធ្យមទាំងប្រភេទជីវភាព និងអាជីវកម្ម។

## ខ- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ដោយយោងទៅតាមការសិក្សានៃតម្រូវការប្រើប្រាស់ទឹកធៀបទៅនឹងកំណើនប្រជាជន នៅក្នុងរាជធានីភ្នំពេញ ដោយសារការពង្រីកតំបន់ជុំវិញរាជធានីភ្នំពេញ រ.ទ.ស.ភ បានធ្វើការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហាន១ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ និងបន្តសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហាន២ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ ដូចគ្នា ដើម្បីបំពេញតម្រូវការទឹកស្អាតនាបច្ចុប្បន្ន និងពេលអនាគត។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមសម្រាប់ប្រព្រឹត្តកម្មទឹកស្អាត អាចប៉ះពាល់ដល់ថ្លៃដើមផលិត ប៉ុន្តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ដោយសារការចំណាយនេះមានអត្រាមិនលើសពី១០% នៃចំណាយប្រតិបត្តិការ។ ទោះជាយ៉ាងណា ក៏ដោយ រ.ទ.ស.ភ ក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាថ្លៃវត្ថុធាតុដើមសមស្របទៅតាមតម្លៃលើទីផ្សារជាក់ស្តែង ហើយនីតិវិធីនេះ ក៏ផ្តល់លទ្ធភាពសម្រាប់ រ.ទ.ស.ភ ទទួលបាននូវតម្លៃប្រកួតប្រជែងដែលមានតម្លៃទាប។

### ៣- ការវិភាគលើពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ច ត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ រ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធអាករ ទៅតាមរបបស្វ័យប្រកាស និងជាសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ខែមីនា ឆ្នាំ២០២២នេះ គណៈគ្រប់គ្រងយល់ថា រ.ទ.ស.ភ ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ រ.ទ.ស.ភ គឺការលក់ទឹកស្អាត ដែលជាតម្រូវការចាំបាច់របស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ។ ចំណូលនេះបានចូលរួមចំណែកប្រមាណ៨៤,២៩% នៃចំណូលសរុបនៅត្រីមាសទី១ឆ្នាំ២០២២ ហើយ រ.ទ.ស.ភ ក៏ជាអ្នក

ផ្គត់ផ្គង់ផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។ ប្រាក់ចំណូលនេះអាចមានការកើនឡើង អាស្រ័យទៅតាមកំណើននៃចំនួនប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ និងតំបន់ទីក្រុងតាខ្មៅផងដែរ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ឃ.១- ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

រ.ទ.ស.ភ បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ"ប្រាក់រៀល"។ប្រតិបត្តិការជារូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅជារូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះការប្តូរទ្រព្យសកម្ម និងបំណុលរូបិយប័ណ្ណបរទេសត្រូវបាន កត់ត្រានៅក្នុងរបាយការណ៍លទ្ធផល លម្អិត។ ដោយសារការទូទាត់ទំនិញរបស់ រ.ទ.ស.ភ ភាគច្រើនធ្វើឡើងដោយប្រាក់រៀល ដូចនេះ រ.ទ.ស.ភ ពុំមានផលប៉ះពាល់ខ្លាំងដោយអត្រាប្តូរប្រាក់នោះទេ។

### ឃ.២- ផលប៉ះពាល់នៃអត្រាការប្រាក់

#### ឃ.២.១- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណូលការប្រាក់

ដោយសារនៅប្រទេសកម្ពុជាពុំមានទីផ្សាររូបិយប័ណ្ណ ដូច្នេះ រ.ទ.ស.ភ មានលទ្ធភាពត្រឹមតែវិនិយោគរយៈពេលខ្លីលើការដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៣ខែ ៦ខែ ៩ខែ និង១ឆ្នាំ នៅធនាគារពាណិជ្ជក្នុងស្រុកតែប៉ុណ្ណោះ។

#### ឃ.២.២- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណាយការប្រាក់

រ.ទ.ស.ភ មានប្រភពហិរញ្ញប្បទានពីរ ដែលមានអត្រាការប្រាក់ថេរ និងប្រែប្រួល។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ ថេរមាន ហិរញ្ញប្បទានដែលទទួលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានកម្រិតអត្រា១,៦៥% និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)មានកម្រិតអត្រា០,៦៦% ក្នុងមួយឆ្នាំ។

ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ប្រែប្រួលមាន ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) នៅអត្រា EURIBOR ៦ខែ ដក១,៣៥ពិន្ទុ។ តែអត្រានេះមិនឲ្យទាបជាង០,២៥% និងមិនខ្ពស់ជាង៥,២១% ក្នុងឆ្នាំនោះទេ។

#### ឃ.២.៣- ផលប៉ះពាល់នៃថ្លៃទំនិញ

តាមរយៈដំណើរការកិច្ចលទ្ធកម្មរបស់ រ.ទ.ស.ភ ដែលអនុលោមទៅតាមច្បាប់ និង បញ្ញត្តិជាធរមាន រួមផ្សំនឹងគោលការណ៍ណែនាំផ្សេងៗ ដែលតម្រូវឲ្យ រ.ទ.ស.ភ ធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់សម្ភារ និងវត្ថុធាតុដើមទៅតាមតម្លៃប្រកួតប្រជែង ឬតម្លៃចរចារួចៗ ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ១៩ ក្នុងត្រីមាសទី១ឆ្នាំ២០២២ បានធ្វើអោយតម្លៃសម្ភារ និងវត្ថុធាតុដើមនៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុកមានការកើនឡើង ដោយសារតម្រូវការ និងការផ្គត់ផ្គង់ពុំមានតុល្យភាព។ ការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើម ក៏បានជះឥទ្ធិពលដល់ចំណាយវិនិយោគ និងចំណាយដំណើរការរបស់ រ.ទ.ស.ភ ផងដែរ។ ប៉ុន្តែទោះបីជាការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើមដូចនេះក្តី គណៈគ្រប់គ្រងបានគិតគូរយ៉ាងហ្មត់ចត់លើផែនការ និងតម្រូវការសម្ភារ បរិក្ខា វត្ថុធាតុដើម ដើម្បីធានាអោយការប្រើប្រាស់បានទាន់ពេល និងមានតម្លៃសមរម្យ ដោយអនុវត្តតាមច្បាប់លទ្ធកម្មសាធារណៈជាធរមាន។

## ង- ផលប៉ះពាល់នៃអតិផរណា

រ.ទ.ស.ភ បានរក្សានូវថ្លៃលក់ទឹកថេរមិនប្រែប្រួលចាប់តាំងពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០១៩។ ដើម្បីធ្វើការកែសម្រួលទៅ តាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្ន ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

ធុរកិច្ចរបស់ រ.ទ.ស.ភ ទទួលការជះឥទ្ធិពលពីគោលនយោបាយមួយចំនួន ដែលកំណត់ដោយរាជរដ្ឋាភិបាលដូចជា៖

- ការពង្រីកផ្ទៃសេវា៖ ការពង្រីកផ្ទៃសេវាបន្ថែមដើម្បីផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរឹតត្បិតដោយបេសកកម្មរបស់ រ.ទ.ស.ភ ដែលអនុញ្ញាតឲ្យផលិត និងចែកចាយទឹកសម្រាប់ការប្រើប្រាស់របស់សាធារណជននៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ការរឹតត្បិតនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ។

- ការពង្រីករាជធានីភ្នំពេញ៖ រាជរដ្ឋាភិបាលមានគោលនយោបាយពង្រីករាជធានីភ្នំពេញ ដោយបញ្ចូលឃុំ បន្ថែមទៀត ទៅក្នុងតំបន់រាជធានីភ្នំពេញដែលធ្វើឲ្យផ្ទៃសេវារបស់ រ.ទ.ស.ភ ក្នុងការផ្គត់ផ្គង់ទឹកស្អាតក៏ត្រូវពង្រីកបន្ថែមដែរ។
- គោលនយោបាយពន្ធលើអចលនទ្រព្យ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឲ្យអនុវត្តនូវ ប្រកាសលេខ ៤៩៣សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី " ការប្រមូលពន្ធលើអចលនទ្រព្យ" ។ អចលនទ្រព្យរបស់ រ.ទ.ស.ភ គឺសម្រាប់បម្រើឲ្យប្រព័ន្ធផលិតកម្មទឹកស្អាត ដែលអចលនទ្រព្យប្រភេទនេះ ត្រូវបានលើកលែងពន្ធ តាមរយៈ សេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០៦សហវ. អពដ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។

## ផ្នែកទី៥: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

ក្នុងត្រីមាសទី១ឆ្នាំ២០២២ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានព័ត៌មានចាំបាច់ផ្សេងទៀតត្រូវបង្ហាញទេ។

# ហត្ថលេខាអភិបាល

# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស២៥
រាជធានីភ្នំពេញ,ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២២
បានអាន និងឯកភាព

ហត្ថលេខា
**អ៊ុំ សុថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស២៥
រាជធានីភ្នំពេញ,ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២២
បានអាន និងឯកភាព

ហត្ថលេខា
**ឡុង ណារ៉ូ**
អភិបាល

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)**

---

: + ៨៥៥(២៣) ៧២៤ ០៤៦

: ir@ppwsa.com.kh

: WWW.PPWSA.COM.KH

---

អគារលេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា